# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

MINISTRY OF ECONOMY AND FINANCE
ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ៦៧៣៣ សហវ.ពណ

ថ្ងៃច័ន្ទ ១០កើត ខែភទ្របទ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០១៩

**ជម្រាបជូន**
**ឯកឧត្តមទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន**

**កម្មវត្ថុ** : ករណីសំណើសុំអនុម័តការចរចាថ្លៃ និងប្រគល់កិច្ចសន្យាស្តីពីការងារជួសជុលចិញ្ចើមផ្លូវដោយក្រាលល្បាយថ្មភ្នំ ចំនួន ០២កំណាត់ ប្រវែងសរុប ២ ១៣០ម (កំណាត់ទី១ ទទឹង ១ម ប្រវែង ៦៥០ម ចាប់ពីគ.ម២២+៤៥០ ដល់គ.ម២៣+១០០ និងកំណាត់ទី២ ទទឹង ២,៥ម ប្រវែង ១ ៤៨០ម ចាប់ពីគ.ម២៥+៩០០ ដល់គ.ម២៧+៣៨០) ស្ថិតលើកំណាត់ផ្លូវខេត្តលេខ២៦១ ក្នុងភូមិបាក់លំពែង ឃុំសំបួរមាស ស្រុកមុខកំពូល ខេត្តកណ្តាល។

**យោង** : -លិខិតលេខ១១២៤០ សហវ.អថ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១៨ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
-កំណត់ហេតុចរចាថ្លៃថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៩ របស់ គ.ល ក្រសួងសាធារណការ និងដឹកជញ្ជូន
-លិខិតលេខ២២៩០ សក.អល ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១៩ របស់ក្រសួងសាធារណការ និងដឹកជញ្ជូន។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុនិងយោងខាងលើ ខ្ញុំសូមជម្រាបជូនឯកឧត្តមទេសរដ្ឋមន្ត្រីជ្រាបថា ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ យល់ព្រមតាមសំណើរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន ប្រគល់កិច្ចសន្យាជូននាយកដ្ឋានវិស្វកម្ម ក្រសួងការពារជាតិ ដើម្បីធ្វើការងារជួសជុលចិញ្ចើមផ្លូវដោយក្រាលល្បាយថ្មភ្នំ ចំនួន ០២កំណាត់ ប្រវែងសរុប ២ ១៣០ម (កំណាត់ទី១ ទទឹង ១ម ប្រវែង ៦៥០ម ចាប់ពីគ.ម២២+៤៥០ ដល់គ.ម២៣+១០០ និងកំណាត់ទី២ ទទឹង ២,៥ម ប្រវែង ១ ៤៨០ម ចាប់ពីគ.ម២៥+៩០០ ដល់គ.ម២៧+៣៨០) ស្ថិតលើកំណាត់ផ្លូវខេត្តលេខ២៦១ ក្នុងភូមិបាក់លំពែង ឃុំសំបួរមាស ស្រុកមុខកំពូល ខេត្តកណ្តាល ក្នុងតម្លៃសរុបចំនួន ១.៣៨៩.០០០.០០០រៀល (មួយពាន់បីរយប៉ែតសិបប្រាំបួនលានរៀលគត់) ជាតម្លៃកិច្ចសន្យា។

ការជួលបន្តទៅឲ្យក្រុមហ៊ុនឯកជនត្រូវបានហាមឃាត់ដាច់ខាត។ បើអង្គភាពរដ្ឋណាមួយគ្មានលទ្ធភាពធ្វើខ្លួនឯងបាន ត្រូវដកហូតប្រគល់ឲ្យអង្គភាពរដ្ឋមួយទៀតជាអ្នកអនុវត្តវិញ។ ក្នុងករណីប្រគល់ឲ្យអង្គភាពរដ្ឋមួយទៀតជាអ្នកអនុវត្ត ត្រូវស្នើសុំការយល់ព្រមពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុជាមុនសិន។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមឯកឧត្តមទេសរដ្ឋមន្ត្រីជ្រាប និងមានវិធានការអនុវត្តបន្តឲ្យសមស្របតាមនីតិវិធីលទ្ធកម្មសាធារណៈតាមការគួរ។

សូមឯកឧត្តមទេសរដ្ឋមន្ត្រី ទទួលនូវគារវកិច្ចពីខ្ញុំ។

ជ. ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
រដ្ឋលេខាធិការ

វង្ស វិសុទ្ធ

<u>ចម្លងជូន</u>
-ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី
-អគ្គនាយកដ្ឋានថវិកា
-សាលាខេត្តកណ្តាល
-នាយកដ្ឋានវិស្វកម្ម ក្រសួងការពារជាតិ
-នាយកដ្ឋានហេដ្ឋារចនាសម្ព័ន្ធសាធារណៈ
-មន្ទីរសាធារណការ និងដឹកជញ្ជូន ខេត្តកណ្តាល
-មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ខេត្តកណ្តាល
-ឯកសារ-កាលប្បវត្តិ